مخالفات الحج والعمرة والزيارة

(للجمعية)

ការប្រពឹត្តខុសក្នុងពេលធ្វើហាជ្ជ

អ៊ុំរ៉ោះ និង ការទស្សនកិច្ច

ការប្រពឹត្តខុសក្នុងពេលធ្វើហាជ្ជ អ៊ុំរ៉ោះ និង ការទស្សនកិច្ច

គណៈកម្មការនៃអង្គការបម្រើការមាតិកាសាសនាអ៊ីស្លាមជាភាសានានា

ការប្រព្រឹត្តខុស និងកំហុសទាក់ទងនឹងការធ្វើអ៊ុំរ៉ោះ

ទីមួយៈ ការប្រពិត្តខុស និងកំហុស របស់មនុស្សក្នុងពេលអៀហរ៉ាម

ការបោះបង់អាល់អៀហឡាល (ការបន្លឺសំឡេងនៀត) ដោយមិនបន្លឺសំឡេងរបស់គាត់បញ្ជាក់ពីការតព្វកិច្ច ដែលគាត់មានបំណងធ្វើវា នៅពេលចាប់ផ្តើមនៀតអៀហរ៉ាម។

ហើយសុណ្ណៈ គឺត្រូវបន្លឺសំឡេងនៀតចំពោះវា

មនុស្សមួយចំនួនគិតស្មានថាអៀហរ៉ាមគឺជាការស្លៀកសម្លៀកបំពាក់អៀហរ៉ាម (ពាក់អ៊ីហ្សារនិងរីហ្ទាក់)

តាមពិតអៀហរ៉ាមគឺៈ ការនៀតចូលធ្វើការតព្វកិច្ច(ហាជ្ជឬអ៊ុំរ៉ោះ) ហើយសញ្ញាសម្គាល់របស់វាគឺអាល់អៀហឡាល(ការបន្លឺសំឡេងនៀត) ជាមួយការតាល់ពីយ៉ះ។ អ្នកណាដែលបានអាល់អៀហឡាល ជាមួយការតាល់ពីយ៉ះព្រមទាំងនៀតធ្វើហាជ្ជ ឬអ៊ុំរ៉ោះ នោះគាត់ស្ថិតក្នុងអៀហរ៉ាមហើយ។

មនុស្សមួយចំនួនគិតស្មានថាការងូតទឹកសម្រាប់អៀហរ៉មគឺជាប្រការរ៉ាំងិប(ចាំបាច់)។

តាមពិតវាជាសុណ្ណះ(គប្បី)
ហើយគ្មានបញ្ហាអ្វីឡើយលើអ្នកដែលបោះបង់ចោលវា។

មនុស្សមួយចំនួនគិតស្មានថាការសឡាត(ថ្វាយបង្គំ)ពីរ៉ក្អាត់បន្ទាប់ពីអៀហរ៉មគឺជាប្រការ៉ាំងិប(ចាំបាច់)
ឬថាវាជាសុណ្ណះពិសេសដែលមិនអាចខ្វះបានហើយពួកគេសឡាតពីរ៉ក្អាត់នេះគ្រប់ពេល។

អ្វីដែលត្រឹមត្រូវគឺច្បាប់បានចែងឱ្យសឡាតមុនពេលអៀហរ៉ម
ប៉ុន្តែវាមិនមែនជាការសឡាតពិសេសសម្រាប់វាទេ។
ប្រសិនបើអ្នកបានសឡាតហ្វារីហ្ទោះ(ហ្វារហ្ទ)
ឬការសឡាតផ្សេងទៀតដែលច្បាប់បានចែង
អ្នកអាចអៀហរ៉មភ្លាមៗបន្ទាប់ពីនោះ។

មនុស្សមួយចំនួនគិតស្មានថាការឈប់នៅមីកត(ព្រំដែនកំណត់)
និងចុះទៅកាន់ម៉ាស្ជិតគឺជាប្រការ៉ាំងិប(ចាំបាច់)។

ការពិតវាមិនមែនជាប្រការ៉ាំងិប(ចាំបាច់)នោះទេ។ អ្នកដែលបានស្លៀកសម្លៀកបំពាក់អៀហរ៉មរួចរាល់និងបានឆ្លងកាត់មីកត
ហើយបានបន្លឺសំឡេងតាល់ពីយ៉ះនៅទីនោះ
ឬនៅចំពីមុខវាខណៈពេលរូបគាត់នៅក្នុងរថយន្តនោះគ្រប់គ្រាន់សម្រាប់គាត់ហើយ។
វាដូចគ្នាទៅនឹងអ្នកនៅលើយន្តហោះដែលបន្លឺសំឡេង

តាល់ពីយ៉ះនៅពេលឆ្លងកាត់
ឬមុនពេលឆ្លងកាត់បន្តិចដើម្បីកុំឲ្យឆ្លងហួសមីកត។
ការប្រើគ្រឿងក្រអូបលើសម្លៀកបំពាក់អៀហរ៉ម។
អ្វីដែលត្រឹមត្រូវ
គឺត្រូវប្រើគ្រឿងក្រអូបនៅលើតែរាងកាយប៉ុណ្ណោះ។
មនុស្សមួយចំនួនគិតស្មានថាការកោររោមប្រដាប់ភេទ ការកាត់ក្រចក
និងការកោររោមក្លៀកគឺជាប្រការរ៉ាំងិប(ចាំបាច់)នៅពេលអៀហរ៉ម
ឬយល់ថាវាជាប្រការសុណ្ណៈសម្រាប់អៀហរ៉ម។
តាមពិតវាគ្រាន់តែជាសុណ្ណៈទូទៅនៅពេលមានតម្រូវការប៉ុណ្ណោះ។
ការអៀហរ៉មមុនពេលដល់មីកត។
នេះផ្តួយពីសុណ្ណៈ
ក៍ប៉ុន្តែអ្នកដែលនៅក្នុងយន្តហោះអាចធ្វើការអៀហរ៉មមុនពេលបន្តិចដើម្បីកុំឲ្យខកខានកន្លែងឆ្លងកាត់ដោយសារល្បឿនយន្តហោះលឿនពេក។ ដូចគ្នានេះដែរប្រសិនបើគាត់ខ្លាចដេកលក់ហើយខកខានការឆ្លងកាត់
គាត់អាចធ្វើអៀហរ៉មមុនពេលតាមតម្រូវការរបស់គាត់។
ការឆ្លងផុតកន្លែងនៀត មីកត(ព្រំដែនកំណត់)ដោយមិនបាននៀតអៀហរ៉ម ដោយសារតែមិនដឹងឬការធ្វេសប្រហែស ឬដោយសារស្ថិតលើយន្តហោះ។

វ៉ាជិប(ចាំបាច់)លើគាត់ដែលឆ្លងជុតមីកត
ដោយមានបំណងធ្វើអ៊ីវ៉ោះ ឬហាដ្ឌី
តែមិនបានចូលនៀតអៀហវ៉មនៅទីនោះគឺ៖
ត្រូវត្រឡប់ទៅ
មីកតនិងចូលនៀតអៀហវ៉មនៅទីនោះវិញ។
ដូចគ្នានេះដែរសម្រាប់អ្នកដែលចុះនៅព្រលានយន្ត
ហោះ ជុតទះ
ហើយមិនបាននៀតអៀហវ៉មលើយន្តហោះដោយមូល
ហេតុណាមួយ៖ ចាំបាច់លើរូបគេត្រូវចេញទៅ
មីកតណាមួយដើម្បីនៀតអៀហវ៉មពីទីនោះ។
ករណីលើកលែង៖
អ្នកដែលមិនឆ្លងកាត់ឬដែលមិនប្រទះនឹង
មីកតណាមួយ គេអាចនៀតអៀហវ៉មនៅជុតទះបាន
ដូចជាប្រជាជនស៊ូដង់ដែលមកដល់តាមយន្តហោះឬ
នាវា លើកលែងតែពួកគេដឹងថាពួកគេឆ្លងកាត់
មីកត យ៉ាឡាំឡាំ ឬ មីកត អាល់ជួសហ្វ៊ះ
តាមផ្លូវដែលពួកគេមក។

ការយល់ខុសអំពីសម្លៀកបំពាក់ម៉ាឌីត
ដែលថាគឺរាល់អ្វីទាំងអស់ដែលមានថ្នេដេ
ដូច្នេះពួកគេជៀសវាងការពាក់ខ្សែក្រវាត់ឬស្បែកជើ
ងដែលមានថ្នេដេ។

បែបនេះមិនត្រឹមត្រូវទេ។ សម្លៀកបំពាក់ម៉ាឌីត
គឺសំដៅលើអ្វីដែលត្រូវបានដេរ
ឬកាត់តាមទំហំរាងកាយ ដូចជាអាវ និងខោ
នៅពេលពាក់តាមរបៀបធម្មតា។

ស្ត្រីពាក់ស្រោមដៃ មុខជាំង (ពួរ៉កក់) ឬ នីកប ឬរជាំងមុខពេញ។

វ៉ាជិប(ចាំបាច់)លើនាង
(នៅពេលនៅចំពោះមុខបុរសដែលមិនមែនជាអ្នកមូហរ៉ម) គឺត្រូវជាំងមុខនិងដៃរបស់នាង ប៉ុន្តែមិនមែនដោយប្រើនីកប ឬស្រោមដៃនោះទេ។ ដោយសារព្យាការី ﷺ បានហាមពីការពាក់វាទាំងពីរ ចំពោះស្ត្រីដែលស្ថិតក្នុងសភាពអៀហរ៉ម។

មនុស្សមួយចំនួនគិតស្មានថាស្ត្រីមានសម្លៀកបំពាក់ពិសេសក្នុងពេលអៀហរ៉ម គឺពណ៌ខ្មៅ ឬបៃតង ឬស។

នេះមិនត្រឹមត្រូវទេ។
សម្រាប់ស្ត្រីអាចស្លៀកសម្លៀកបំពាក់អ្វីក៏បានតាមតែនាងពេញចិត្តក្នុងពេលអៀហរ៉ម
ដោយគ្រាន់តែមិនបង្ហាញការតុបតែងខ្លួនបុណ្ណោះ។

មនុស្សមួយចំនួនគិតស្មានថាមិនអនុញ្ញាតឲ្យផ្លាស់ប្តូរ ឬដោះសម្លៀកបំពាក់អៀហរ៉មឡើយ។

អ្វីដែលត្រឹមត្រូវគឺអ្នកដែលកំពុងនៅក្នុងសភាពអៀហរ៉មអាចផ្លាស់ប្តូរ
ឬបោកសម្អាតរួចពាក់វាឡើងវិញបាន។

អាល់អ៊ីតឌីហ្គាក់(ការបើកស្មាខាងស្តាំ)
គឺចាប់ផ្តើមពីដំបូងរហូតដល់ចប់នៃអៀហរ៉ម។

ដែលត្រឹមត្រូវអាល់អ៊ីតឌីហ្គាក់(ការបើកស្មាខាងស្តាំ) ត្រូវបានអនុញ្ញាតតែក្នុងពេលតវ៉ាហ្វអ៊ីរ៉ះឬ តវ៉ាហ្វ គូទូម (ការមកដល់) ប៉ុណ្ណោះ។

ការបោះបង់ចោលអៀហរ៉ាមនិងចេញពីសភាពអៀហរ៉ាមដោយគ្មានហេតុផលច្បាប់ត្រឹមត្រូវលើរឿងនោះ។

វ៉ាជីប(ចាំបាច់)លើបុគ្គលដែលស្ថិតក្នុងស្ថានភាពអៀហរ៉ាម(អ្នកបំពេញការធ្វើហាជ្ជីឬអ៊ុំរ៉ោះ) ត្រូវស្ថិតនៅក្នុងសភាពអៀហរ៉ាមរហូតដល់បញ្ចប់កាតព្វកិច្ចហាជ្ជី ឬ អ៊ុំរ៉ោះរបស់ខ្លួន លើកលែងតែមានមូលហេតុស្របច្បាប់សម្រាប់ការចេញពីអៀហរ៉ាម គឺការរារាំង(ដោយសារជំងឺ ឬសត្រូវ) ក្នុងករណីនេះ គាត់អាចចេញពីអៀហរ៉ាមបាន។ ប្រសិនបើគាត់បានដាក់លក្ខខណ្ឌនៅពេលចូលអៀហរ៉ាម គាត់មិនត្រូវបង់ជាកអ្វីទេ។ ប៉ុន្តែប្រសិនបើគាត់មិនបានដាក់លក្ខខណ្ឌទេ ចាំបាច់លើគាត់ត្រូវសំឡេះសត្វជាការពិន័យ ហើយត្រូវកោរសក់ ឬកាត់សក់បន្ទាប់មកចេញពីអៀហរ៉ាម។

***

ទី២.

ការប្រព្រឹត្តខុសនិងកំហុសឆ្គងរបស់មនុស្សក្នុងពេលតវាហ្វ (ការដើរជុំវិញកាក់ហ្គ៉ះ):

ការសូត្រទូអា(ការបួងសួង)ដែលមិនមានក្នុងសុណ្ណៈអំឡុងពេលចូលម៉ាស្ជិតហារ៉ាម ឬពេលឃើញកាក់ហ្គ៉ះ

ស៊ុណ្ណៈគឺត្រូវកំណត់យកទៅតាមអ្វីដែលបានរាយការណ៍ពីព្យាការីមូហាំម៉ាត់ ﷺ។

ការនៀតដោយបញ្ចេញសំលេងមុនពេលចាប់ផ្តើមតវ៉ាហ្វ

ការនៀតគឺនៅក្នុងចិត្ត
ច្បាប់មិនអនុញ្ញាតបញ្ចេញសំលេងឡើយ។

ការប៉ងចាប់ផ្តើមតវ៉ាហ្វមុនពេលដល់ហាដើរ៉ុលអាស្វាត(ដុំថ្មខ្មៅ) គ្រាន់តែដើម្បីសុវត្ថិភាព។

នេះគឺជាការប្រុងប្រយ័ត្នជ្រុលពេកហើយ។

ការចាប់ផ្តើមតវ៉ាហ្វបន្ទាប់ពីឆ្លងផុតហាដើរ៉ុលអាស្វាត ដោយចាត់ទុកថានោះគឺបានមួយដុំ។

បែបនេះមិនត្រឹមត្រូវទេ
ប្រសិនបើធ្វើដូច្នោះគេមិនអាចចាត់ទុកវាថាមួយដុំនោះទេ។

ការលើកដៃទាំងពីរនៅពេលទៅដល់ហាដើរ៉ុលអាស្វាត ដូចក្នុងពេលសឡាត
ឬការលើកដៃទាំងពីរបីដង
។

ស៊ុណ្ណះគឺត្រូវលើកដៃស្តាំតម្រង់ទៅកាន់វាតែមួយដងប៉ុណ្ណោះ។

ការឈប់យូរនៅកន្លែងហាដើរ៉ុលអាស្វាត

ស៊ុណ្ណះគឺមិនត្រូវឈប់យូរពេកទេ។

ការប្រជ្រាតគ្នាខ្លាំងដើម្បីទៅដល់ហាដើរ៉ុលអាស្វាត ដើម្បីថើបវា

ស៊ុណ្ណះគឺមិនត្រូវប្រជ្រាតគ្នាឡើយ
ប្រសិនបើអាចទៅដល់វាដោយគ្មានការប្រជ្រាតគ្នាចូរ

ធ្វើចុះ បើមិនអាចទេ
គ្រាន់តែលើកដៃគឺគ្រប់គ្រាន់ហើយ។

ការត្រឡប់ក្រោយពេលឆ្លងផុតហាដើរ៉ុលអាស្វាត
ដោយមិនបានតឹកពៀរ ដើម្បីលើកដៃនិងតឹកពៀរ
ឬការតឹកពៀរបន្ទាប់ពីឆ្លងផុតវា

ទាំងអស់នេះគឺមិនត្រឹមត្រូវឡើយ។
វាគ្រាន់តែជាសុណ្ឌះបើឆ្លងផុតកន្លែងវាមិនចាំបាច់ត្រូ
វត្រឡប់ក្រោយដើម្បីធ្វើវាទេ
ហើយមិនមានបញ្ហាអ្វីឡើយសម្រាប់អ្នកដែលភ្លេចតឹ
កពៀរឬបោះបង់វាដោយចេតនានោះ។

ការកំណត់ទូអា(ការបួងសួង)ជាក់លាក់សម្រាប់ជុំ
នីមួយៗ។

ហើយគ្មានភស្តុតាងណាមួយចំពោះរឿងនេះទេ។
តាមសុណ្ឌះ អ្នកតវ៉ាហ្វទាំងឡាយ
អាចទូអា(បួងសួង)សុំប្រការល្អផ្សេងៗទាំងក្នុងលោកិ
យនិងបរលោកតាមអ្វីដែលគេពេញចិត្ត
និងរំឭកដល់អល់ឡោះ
នូវការរំឭកដែលច្បាប់បានចែង ដូចជា
តាស់ពេស(ស៊ុបហាណុលឡោះ)
ឬតះមីត(អាល់ហាំទូលិលឡោះ)
ឬតះលេល(ឡើអ៊ីឡើហើរអ៊ីលលុលឡោះ) ឬតឹកពៀរ
(អល់ឡហ៊ូអឹកប្ពារ) ឬការសូត្រគួរអាន។

ការរត់តិចៗគ្រប់ជុំនៃតវ៉ាហ្វ។

តាមសុណ្ឌះគឺត្រូវធ្វើវានៅក្នុងបីជុំដំបូងប៉ុណ្ណោះ។

ការមិនដាក់កាក់ហ្គះនៅខាងឆ្វេងដៃគេក្នុងពេលតវ៉ាហ្វដោយគ្មានហេតុផលត្រឹមត្រូវ។

តាមសុណ្ឌះ កាក់ហ្គះត្រូវនៅខាងឆ្វេងដៃគេដូច្នេះមិនគាប់បីឡើយលើគេធ្វេសប្រហែសធ្វើផ្តួយពីនោះ។

តែប្រសិនបើគេមានហេតុផលសមស្របដូចជាមានមនុស្សច្រើនកកកុញ ឬផ្សេងពីទៀតនោះអ្នកមិនមានបញ្ហានោះទេ។

ការថើបជ្រុងយ៉ាម៉ានី
ឬការលើកដៃតម្រង់ទៅវានៅពេលមិនអាចថើបវា។

តាមសុណ្ឌះគឺគ្រាន់តែប៉ះវាដោយដៃប៉ុណ្ណោះដោយមិនថើបវានោះទេ។ ប្រសិនបើមិនអាចប៉ះវា គេមិនត្រូវលើកដៃតម្រង់ទៅកាន់វាទេ។

ការប៉ះនិងថើបគ្រប់ជ្រុងនៃកាក់ហ្គះ
ឬជញ្ជាំងរបស់វា ហើយនិងការប៉ះពាល់វា។

នេះគឺផ្តួយពីសុណ្ឌះ ព្រោះច្បាប់មិនបានចែងឡើយលើកលែងតែការថើបហាដើរ៉ុលអាស្វាត(ថ្មខ្មៅ) និងប៉ះជ្រុងយ៉ាម៉ានីប៉ុណ្ណោះ។

ការគិតស្មានថាការប៉ះជ្រុងយ៉ាម៉ានី
និងហាដើរ៉ុលអាស្វាត គឺដើម្បីទទួលបានពរជ័យមិនមែនជាការប្រណិប័តន៍ទេ។

ទាំងអស់នេះគឺជាភាពល្ងង់ខ្លៅ និងភាពវង្វេងព្រោះផលប្រយោជន៍
និងគ្រោះថ្នាក់គឺស្ថិតនៅក្នុងព្រះហស្តរបស់អល់ឡោះតែមួយគត់។ ដូចដែលអ៊ូម៉ើរ

(សូមអល់ឡោះពេញចិត្តដល់គាត់)
បានមកកាន់ហាជើរ៉ុលអាស្វាត(ថ្មខ្មៅ) ហើយថើបវា
រួចនិយាយថា៖ "ខ្ញុំដឹងថាអ្នកគ្រាន់តែជាដុំថ្ម
មិនអាចបង្កគ្រោះថ្នាក់ ឬផ្តល់ផលប្រយោជន៍បានទេ
ហើយប្រសិនបើខ្ញុំមិនបានឃើញព្យាការី ﷺ ថើបអ្នក
ខ្ញុំក៏នឹងមិនថើបអ្នកដែរ"
ការបន្លឺសម្លេងខ្លាំងក្នុងពេលទូអា(បួងសួង)
ដែលនាំឱ្យរំខានដល់អ្នកតវ៉ាហ្វដទៃទៀត។
តាមសុណ្ឌែះគួររំឭកទៅចំពោះឡោះជាម្ចាស់
និងទូអា(បួងសួង)ដោយសំលេងតិចៗលឺត្រឹមខ្លួនឯ
ងបានហើយ ដើម្បីកុំឱ្យរំខានអ្នកដទៃ។
ការរវល់ក្នុងការថតរូប
ឬការសន្ទនាផ្សេងៗក្នុងពេលធ្វើតវ៉ាហ្វ។
ច្បាប់បានចែងសម្រាប់អ្នកតវ៉ាហ្វគឺត្រូវស្ថិតក្នុងការ
រំឭកចំពោះអល់ឡោះជាម្ចាស់ដោយការកោតខ្លាច
ឱនលំទោន និងដាក់ចិត្ត ផ្ចង់អារម្មណ៍។
ការបញ្ចប់តវ៉ាហ្វមុនពេលប្រាកដថាបានមកដល់
ហាជើរ៉ុលអាស្វាត(ថ្មខ្មៅ)។
រ៉ាជិប(ចាំបាច់)ត្រូវបំពេញដុំទី៧
រហូតដល់អ្នកប្រាកដ
ឬជឿជាក់ថាអ្នកបានមកដល់កន្លែងហាជើរ៉ុលអាស្វា
ត(ថ្មខ្មៅ) ។
ការគិតថាសឡាត(ការថ្វាយបង្គំ)ពីរ៉ក្អាត់បន្ទាប់ពី
តវ៉ាហ្វនោះចាំបាច់ត្រូវតែអនុវត្តនៅពីក្រោយម៉ាកម
អ៊ីព្រហ៊ីមដោយផ្ទាល់ ឬនៅជិតនោះ

ធ្វើឱ្យមានការណ៍ប្រមូលផ្តុំគ្នាដែលបង្កការរំខានដល់
អ្នកតវ៉ាហូរចេញទៅក្នុងរដូវហាជ្ជី
និងរារាំងដំណើរតវ៉ាហូរបស់ពួកគេ។
នេះជាការយល់ខុស
សឡាត(ការថ្វាយបង្គំ)ពីរ៉ក្អាត់បន្ទាប់ពីតវ៉ាហូអាចអ
នុវត្តនៅគ្រប់កន្លែងក្នុងម៉ាស្ជិត
ហើយអ្នកសឡាតអាចដាក់ម៉ាកមអ៊ីព្រហ៊ីមនៅចន្លោះ
គាត់និងកាកុំ
(ទោះបីជានៅឆ្ងាយពីម៉ាកមក៏ដោយ)
ហើយគាត់អាចធ្វើសឡាតនៅក្នុងបរិវេណឬរបងម៉ាស្ជិ
តរួចផុតពីការរំខាន
និងទទួលបានផលបុណ្យនៃការសឡាតដោយក្តីកោត
ខ្លាចនិងភាពស្ងប់ស្ងាត់។
ការសឡាតពីរ៉ក្អាត់បន្ទាប់ពីតវ៉ាហូ
និងការទូអាក្រោយពីនោះយូរពេក។
តាមសុណ្ណៈគឺត្រូវធ្វើវាឱ្យលឿន
និងមិនត្រូវទូអាអ្វីបន្ទាប់ពីរ៉ក្អាត់ទាំងពីរនោះទេ
ព្រោះមិនមានការរាយការណ៍ពីព្យាការីﷺ។
ការសឡាតពីរ៉ក្អាត់បន្ទាប់ពីតវ៉ាហូបើកស្ពា។
តាមសុណ្ណៈគឺត្រូវគ្របដណ្តប់ស្មាវិញភ្លាមៗបន្ទាប់ពី
បញ្ចប់តវ៉ាហូរួច។
***

ទី៣.

ការប្រព្រឹត្តខុសនិងកំហុសឆ្គងរបស់មនុស្សក្នុងការពេលសារ៉ី

ការបើកស្មាខាងស្តាំអំឡុងពេលសារ៉ី។

បានលើកឡើងរួចហើយថា
ការបើកស្មាខាងស្តាំត្រូវធ្វើតែក្នុងពេលធ្វើតវ៉ាហ្វប៉ុណ្ណោះ។

ការបញ្ចេញសំលេងនៀតមុនចាប់ផ្តើមសារ៉ី។

បានលើកឡើងរួចហើយថា នៀតគឺនៅក្នុងចិត្ត ហើយការបញ្ចេញសំលេងនៀតខុសពីអ្វីដែលច្បាប់បានចែង។

ការចាប់ផ្តើមពីភ្នំម៉ារ៉ះក្នុងពេលធ្វើសារ៉ី។

នេះមិនត្រឹមត្រូវទេ
ហើយជនណាដែលធ្វើបែបនោះគេមិនចាត់ទុកវាមួយជុំឡើយ។

មនុស្សមួយចំនួនគិតស្មានថាមួយជុំគឺគិតទាំងទៅនិងត្រឡប់មកវិញ ដូច្នេះពួកគេធ្វើសារ៉ី១៤ជុំ។

នេះមិនត្រឹមត្រូវទេ
ពីព្រោះការដើរពីភ្នំសហ្វាទៅភ្នំមរ៉ាគឺមួយជុំ
ហើយពីភ្នំម៉ារ៉ះទៅភ្នំសហ្វាគឺ១ជុំ
ការចាប់ផ្តើមត្រូវតែពីភ្នំសហ្វា
ហើយបញ្ចប់នៅភ្នំម៉ារ៉ះ។

ការឡើងទៅកំពូលភ្នំសហ្វាដោយគិតថាវាចាំបាច់។

គ្មានភស្តុតាងបញ្ជាក់ថាវាជាលក្ខខណ្ឌចាំបាច់នោះទេ។

ការលើកដៃទាំងពីរ
និងការចង្អុលដូចដែលធ្វើក្នុងតឹកពៀរពេលសឡាត។

អ្វីដែលត្រឹមត្រូវគឺគ្រាន់តែងាកទៅរកគីបឡាត់
និងទូអាតាមអ្វីដែលមានក្នុងស៊ុណ្ណះ។

ការធ្វើសាអ៊ុយ៉ាងលឿនរបស់ស្ត្រីរវាងសញ្ញាសម្គាល់
ទាំងពីរដូចបុរស។

អ្វីដែលត្រឹមត្រូវសម្រាប់នាងគឺគ្រាន់តែដើរធម្មតា
ដែលជាការឯកភាពរបស់អ៊ូឡាម៉ាក់ទាំងអស់
ដើម្បីការពារនាងពីការបង្ហាញខ្លួន។

ការកំណត់ទូអាជាក់លាក់សម្រាប់ជុំនីមួយៗនៃការ
ធ្វើសាអ៊ុ។

រឿងនេះគ្មានកស្តុតាងណាមួយបញ្ជាក់ទេ
ប៉ុន្តែត្រូវសូត្រទូអាណាដែលខ្លួនពេញចិត្តដោយមិនកំ
ណត់។

ការបន្លឺសំលេងខ្លាំងនៅក្នុងពេលសាអ៊ុដែលបណ្តា
លឱ្យមានការរំខានដល់អ្នកដទៃ។

តាមសុណ្ណះគឺត្រូវរំឭកដល់អល់ឡោះជាម្ចាស់របស់គេ
និងទូអារលឺត្រឹមខ្លួនឯង
ដើម្បីកុំឱ្យរំខានដល់អ្នកដទៃ។

ការប្រញាប់ប្រញាល់ក្នុងការធ្វើសាអីរវាងភ្នំសហ
និងម៉ារ៉ះគ្រប់ជុំ។

តាមសុណ្ណះគឺត្រូវប្រញាប់ប្រញាល់ខ្លាំងតែនៅច
ន្លោះសញ្ញាសម្គាល់បៃតងទាំងពីរប៉ុណ្ណោះ។

ការសឡាតពីរ៉ក្អាត់បន្ទាប់ពីបញ្ចប់ការធ្វើសាអ៊ុ។

រឿងនេះគ្មានភស្តុតាងណាមួយបញ្ជាក់ទេ ដូច្នេះវាមិនត្រូវបានអនុញ្ញាតឱ្យធ្វើនោះទេ។

ការធ្វើសាអីស្ម័គ្រចិត្តក្រៅពីហាដ្ឋី។

ការធ្វើសាអីមិនត្រូវបានអនុញ្ញាតឱ្យធ្វើស្ម័គ្រចិត្តឡើយ។

***

ទី៤៖

ការប្រព្រឹត្តខុសនិងកំហុសរបស់មនុស្សក្នុងការកោរសក់ ឬកាត់សក់

ការមិនយកចិត្តទុកដាក់នៅពេលកោរសក់ ឬកាត់សក់ពេញក្បាល។

តាមសុណ្ណះគឺត្រូវកោរសក់ ឬកាត់សក់ពេញក្បាល។

ការកោរសក់ ឬកាត់សក់នៅក្នុងម៉ាស្ជិតហារ៉ម(វិហារដ៏ពិសិដ្ឋ) ហើយបោះសក់ចោលនៅទីនោះ។

រ៉ាំជិប(ចាំបាច់)គឺត្រូវលើកតម្កើងម៉ាស្ជិតហារ៉ម និងថែរក្សាភាពស្អាតរបស់វា។

ការពន្យារពេលកោរសក់ ឬកាត់សក់យូរពេក អាចនាំឲ្យភ្លេច ឬរល់នឹងការផ្សេងៗ។

ច្បាប់តម្រូវឱ្យធ្វើភ្លាមៗបន្ទាប់ពីបញ្ចប់ការដើរជុំវិញកាក់ហ្គ៉ះ និងការដើររវាងភ្នំសហ្វានិងម៉ារ៉ះ។

ការធ្វើប្រការដែលគេហាមឃាត់អំឡុងពេលអៀហរ៉ម មុនពេលកោរសក់ ឬកាត់សក់។

រ៉ាងិប(ចាំបាច់)គឺមិនត្រូវធ្វើប្រការដែលគេហាមឃាត់ឡើយ លើកលែងតែបន្ទាប់ពីកោរសក់ឬកាត់សក់រួច។

***

ការប្រព្រឹត្តខុស
និងកំហុសទាក់ទងនឹងពេលធ្វើហាជ្ជ

ទីមួយៈ
ការប្រព្រឹត្តខុសនិងកំហុសរបស់មនុស្សក្នុងថ្ងៃតារ៉ាវីយ៉ៈ

មនុស្សមួយចំនួនគិតស្មានថាការចូលក្នុងអៀហរ៉ាមនៅថ្ងៃតារ៉ាវីយ៉ៈ គួរធ្វើពីម៉ាស្ជិតហារ៉ាម ឬពីក្រោមទីកបង្ហូរ (មីហ្សាប)។

តាមសុណ្ណៈគឺត្រូវចូលអៀហរ៉ាមពីកន្លែងដែលគាត់កំពុងស្ថិតនៅ ទោះបីនៅម៉ាក្កៈ ឬនៅមីណាក៏ដោយ។

ការពន្យារពេលការចូលអៀហរ៉ាមដល់ក្រោយពេលសឡាតហ្ស៊ូហ៊ូរ។

តាមសុណ្ណៈគឺត្រូវចូលអៀហរ៉ាមសម្រាប់ហាជ្ជីនៅពេលព្រឹកមុនសឡាតហ្ស៊ូហ៊ូរ។

ការមិនស្នាក់នៅមីណាខណៈដែលមានលទ្ធភាពធ្វើវា។

តាមសុណ្ណៈសម្រាប់អ្នកធ្វើហាជ្ជីគឺត្រូវស្នាក់នៅមីណាបើសិនជាគាត់មានលទ្ធភាព
ដោយសារតែវាជាទង្វើរបស់ព្យាការីមូហាំម៉ាត់ ﷺ ។

ការសឡាតហ្គាម៉ក(សឡាតរួម) នៅមីណា។

តាមសុណ្ឌះគឺត្រូវសឡាតក៏ស័រ(សឡាតខ្លី)
នៅមីណាដោយមិនសឡាតហ្គាម៉ក(សឡាតរួម)ទេ
អនុវត្តតាមព្យាការីមូហាំម៉ាត់ﷺ។

***

ទី២.

ការប្រព្រឹត្តខុសនិងកំហុសរបស់មនុស្សក្នុងថ្ងៃអារ៉ហ្វះ

ការស្ថិតនៅអារ៉ហ្វះនៅក្នុងថ្ងៃទី៨
ដោយសារការប្រុងប្រយ័ត្ន
នេះគឺជាការលំបាក
និងប្រព្រឹត្តជ្រុលដែលត្រូវបានហាមឃាត់។
ការចេញទៅអារ៉ហ្វះពីថ្ងៃទី៨ ឬយប់ទី៩
និងការស្នាក់នៅទីនោះ
នេះផ្តួយពីសុណ្ឌះ
និងធ្វើឱ្យបាត់បង់សុណ្ឌះនៃការស្នាក់នៅមីណា។
ការស្ថិតនៅក្រៅព្រំដែននៃអារ៉ហ្វះ
រ៉ាជិប(ចាំចាច់)លើអ្នកធ្វើហាជ្ជីត្រូវប្រាកដថាគាត់
ស្ថិតនៅក្នុងព្រំដែននៃអារ៉ហ្វះ។
ការគិតស្មានថាចាំបាច់ត្រូវសឡាតជាមួយអ៊ីមុាំនៅ
ម៉ាស្ជិតណាមុីរ៉ះ
និងការប្រជ្រាតគ្នារញ៉ៃរញ៉ៃខ្លាំងដើម្បីស្នាក់នៅនៅទី
នោះ
មិនចាំបាច់ធ្វើបែបនេះទេ
ហើយច្បាប់ក៏មិនបានចែងឱ្យប្រជ្រាតគ្នាដើម្បីធ្វើដូ
ច្នោះនោះដែរ។
ការតម្រង់មុខទៅភ្នំ (អីឡាល់) នៅពេលសុំទូអា

សុណ្ណៈគឺត្រូវតម្រង់ទៅកាន់គីបឡាត់។

ការជឿថាការឡើងទៅភ្នំអីឡាល់ជាកាតព្វកិច្ច ឬវាជាផ្នែកមួយនៃការធ្វើហាជ្ជ ឬវាមានគុណសម្បត្តិ ឬអត្ថប្រយោជន៍លើទីកន្លែងដទៃទៀតនៃអារ៉ហ្វះ

គ្មានភស្តុតាងបញ្ជាក់លើរឿងនេះឡើយ ពិតណាស់វាផ្ទុយពីការណែនាំរបស់ព្យាការីមូហាំម៉ាត់។

ការហៅឈ្មោះភ្នំ (អីឡាល់) ថាភ្នំរ៉ៈម៉ះ ឬ (ភ្នំនៃការសុំទូអា)

អ្វីដែលត្រឹមត្រូវគឺឈ្មោះរបស់វា (អីឡាល់) ហើយគ្មានភស្តុតាងនៃការហៅវាថាភ្នំរ៉ៈម៉ះ ឬភ្នំសុំទូអានោះទេ។

ការចូលទៅក្នុងគុបហ្គះដែលនៅលើភ្នំអារ៉ហ្វះ និងការហៅវាថាគុបហ្គះអាទាំ ការសឡាតនៅក្នុងវា និងការដើរជុំវិញវាដូចការដើរជុំវិញកាក់ហ្គះ

ទាំងអស់នេះជាការបង្កើតថ្មីដែលត្រូវបានហាមឃាត់ ហើយវាអាចឈានដល់ការប្រព្រឹត្តិស៊ីរិក។

ការស្វែងរកពរជ័យពីបង្គោលដែលដាក់នៅលើភ្នំរ៉ៈម៉ះនៅអារ៉ហ្វះ និងការសរសេរឈ្មោះលើវា

ទាំងអស់នេះជាការបង្កើតថ្មីដែលត្រូវបានហាមឃាត់ ហើយអាចឈានដល់ការប្រព្រឹត្តិស៊ីរិក។

ការដាក់លុយនៅក្នុងចន្លោះនៅលើភ្នំអារ៉ហ្វះ ឬភ្នំនួរ ឬការដាក់សក់ ឬក្រចក ឬអ្វីមួយពីសម្លៀកបំពាក់ជាដើម ដោយជឿថាវានាំឱ្យម្ចាស់របស់វាត្រឡប់មកកន្លែងទាំងនេះវិញ

ទាំងអស់នេះគឺជាការបង្កើតថ្មីដែលត្រូវបានហាមឃាត់ ហើយអាចឈានដល់ការប្រព្រឹត្តិសុីរីក។

មនុស្សមួយចំនួនគិតស្មានថាចាំបាច់ត្រូវឈរនៅទីតាំងរបស់ព្យាការី ឬពួកគេព្យាយាមធ្វើវា។

អ្វីដែលត្រឹមត្រូវ វាមិនមែនជាវ៉ាជិប(ចាំបាច់)ទេ ហើយការព្យាយាមធ្វើវាមិនត្រូវបានណែនាំនោះទេ។

ការខ្ជះខ្ជាយពេលវេលា ការបោះបង់ការសុំទូអា និងការហ្ស៊ីកៀត
ដោយរវល់ជាមួយអ្វីដែលមិនមានប្រយោជន៍។

ការពន្យារពេលចាប់ផ្តើមការសុំទូអារហូតដល់ជិតព្រះអាទិត្យលិច ឬចុងបញ្ចប់នៃថ្ងៃ។

ការដាក់បន្ទុកខ្លួនឯងឱ្យឈរសុំទូអា
ដោយគិតស្មានថាវាជាស៊ុណ្ណះ
ឬការគិតស្មានថាអត្ថន័យនៃការស្ថិតនៅអារ៉ហ្វះគឺការឈរដើម្បីសុំទូអា។

អ្វីដែលត្រឹមត្រូវ
ការស្ថិតនៅអារ៉ហ្វះមានន័យថាត្រូវការស្ថិតនៅទីនោះក្នុងពេលនោះ ទោះបីជាឈរ ឬអង្គុយ ជិះយានឬដើរក៏ដោយ។

ការចាកចេញពីអារ៉ហ្វះមុនពេលព្រះអាទិត្យលិច។

នេះជាប្រការហារ៉ម(ហាមឃាត់)
ព្រោះវាផ្ទុយនឹងស៊ុណ្ណះរបស់ព្យាការី។

ការពន្យារពេលចាកចេញបន្ទាប់ពីព្រះអាទិត្យលិច
ដោយគ្មានមូលហេតុសមរម្យ។

តាមស៊ុណ្ណះគឺត្រូវប្រញាប់ចាកចេញភ្លាមៗបន្ទាប់ពីព្រះអាទិត្យលិច លើកលែងតែមានមូលហេតុសមរម្យ។

មនុស្សខ្លះយល់ថាការស្ថិតនៅអារ៉ាហ្វះចំថ្ងៃសុក្រស្មើនឹងការធ្វើហាជ្ជ ៧០ ដង។

វាគ្មានភស្តុតាងបញ្ជាក់លើរឿងនេះនោះទេ។

***

ទី៣.

ការប្រព្រឹត្តខុសនិងកំហុសរបស់មនុស្សក្នុងការធ្វើដំណើរទៅកាន់មូហ្សូទើលីហ្វះ និងការស្នាក់នៅទីនោះ

ការប្រញាប់ប្រញាលក្នុងពេលចាកចេញពីអារ៉ាហ្វះ និងបង្កការរំខានដោយរថយន្ត

តាមសុណ្ណះគឺការចាកចេញដោយស្ងប់ស្ងាត់ និងដោយក្តីគោរព
ព្រមទាំងមិនបង្កការឈឺចាប់ដល់អ្នកដទៃ។

មនុស្សមួយចំនួនគិតស្មានថាច្បាប់តម្រូវឱ្យឆ្លងទឹកសម្រាប់អ្នកស្នាក់នៅមូហ្សូទើលីហ្វះ

គ្មានភស្តុតាងណាដែលបញ្ជាក់ពីបទបញ្ជត្តិនេះទេ។

មនុស្សមួយចំនួនគិតស្មានថាគួរចុះពីយានដំនិះដើម្បីចូលទៅមូហ្សូទើលីហ្វះដោយថ្មើរជើង

គ្មានភស្តុតាងណាដែលបញ្ជាក់ពីបទបញ្ជត្តិនេះទេ។

ការចុះនៅកន្លែងមួយដោយមិនបានប្រាកដថាវាស្ថិតនៅក្នុងព្រំដែននៃមូហ្សូទើលីហ្វះ

ការមិនប្រញាប់ប្រញាល់ក្នុងការសឡាតនៅពេលដំបូងនៃការមកដល់មូហ្សូទើលីហ្វះ

តាមសុណ្ឌះត្រូវប្រញាប់ប្រញាល់ក្នុងការសឡាតភ្លាម
ៗនៅពេលមកដល់មូហ្សូទើលីហ្វ៉ះ

ការរង់ប្រមូលដុំគ្រួសភ្លាមៗនៅពេលចូលដល់មូហ្សូ
ទើលីហ្វ៉ះ
និងការយកចិត្តទុកដាក់អំពីដុំគ្រួសដោយគិតស្មាន
ថារាជាបទបញ្ញត្តិ

គ្មានភស្តុតាងណាដែលបញ្ជាក់ពីរឿងនេះទេ។

ការពន្យារពេលសឡាតម៉ាហ្គ្រីប
និងអ៊ីសាហួតដល់ផុតពេលវេលារបស់វា
គឺពាក់កណ្តាលអាធ្រាត្រ

រ៉ាជីប(ថាំបាច់)គឺត្រូវសឡាតម៉ាហ្គ្រីប
និងអ៊ីសាមុនពាក់កណ្តាលអាធ្រាត្រ
ទោះបីជាមុនពេលមកដល់មូហ្សូទើលីហ្វ៉ះក៏ដោយ។

ការរក្សាយប់នៅមូហ្សូទើលីហ្វ៉ះ ដោយសឡាត
ឬការគោរពសក្ការៈ ឬការកម្សាន្ត និងការលេងសើច

តាមសុណ្ឌះគឺការប្រញាប់ប្រញាល់ក្នុងការគេង
និងការសម្រាក តាមគំរូព្យាការីមូហាំម៉ាត់ﷺ
ដើម្បីទទួលបានកម្លាំងសម្រាប់បំពេញការតាឰកិច្ច
នៅថ្ងៃបុណ្យរ៉ាយ៉ាហាដ្ឋី។

ការចាកចេញរបស់អ្នកទន់ខ្សោយ
និងអ្នកអមដំណើរមុនពាក់កណ្តាលអាធ្រាត្រ

រ៉ាជិប(ថាំបាច់)គឺពួកគេមិនត្រូវចាកចេញរហូត
ក្រោយពាក់កណ្តាលអាធ្រាត្រ។

ការចាកចេញរបស់អ្នកដែលមិនមែនជាអ្នកទន់ខ្សោយ
និងមិនមានអ្នកទន់ខ្សោយនៅជាមួយមុនពេលថ្ងៃរះ
រ៉ាជីប(ចាំបាច់)លើពួកគេគឺត្រូវស្នាក់នៅមូហ្សូទើលីហ្វ៉ះ រហូតដល់ថ្ងៃរះ។
ការយឺតយ៉ាវក្នុងការចាកចេញពីមូហ្សូទើលីហ្វ៉ះ រហូតដល់ព្រះអាទិត្យរះ
តាមសុណ្ឌះគឺត្រូវការចាកចេញពីទីនោះមុនពេលព្រះអាទិត្យរះ។
***

ទី៤.

ការប្រព្រឹត្តខុសនិងកំហុសរបស់មនុស្សក្នុងការអនុវត្តទង្វើនៅថ្ងៃណារ៍(ថ្ងៃសំឡេះសត្វ)

មនុស្សខ្លះគិតស្មានថាច្បាប់តម្រូវឱ្យងូតទឹកមុនពេលគប់គោល។
គ្មានភស្តុតាងបញ្ជាក់លើការកំណត់បែបនេះឡើយ។
ការលាងគ្រាប់ក្រួសមុនពេលគប់។
គ្មានភស្តុតាងបញ្ជាក់លើការកំណត់បែបនេះឡើយ។
ការជឿថាការគប់គោលមិនត្រឹមត្រូវទេលុះត្រាតែគ្រាប់ក្រួសនោះប្រមូលពីមូហ្សូទើលីហ្វ៉ះ។
គ្មានភស្តុតាងបញ្ជាក់លើរឿងនេះទេ
គាត់អាចរើសគ្រាប់ក្រួសពីកន្លែងណាក៏បាន។

ការគប់គោលដោយមិនប្រើគ្រាប់ក្រួស
ឬការប្រើក្រួសធំពេក។
បែបនេះគឺផ្ទុយពីការអនុវត្តរបស់ព្យាការី ﷺ។
ក្រោកខឹងពេលគប់គោល
និងជឿថាគោលគឺជាសៃតន។
ការប្រមូលផ្តុំ
និងភ្ជាប់គ្នាជាក្រុមពេលទៅគប់គោល
និងបង្កការរំខានដល់អ្នកដទៃ។
ការបន្ថែមពាក្យលើការស៊ីកៀតពេលគប់គោល។
ដែលល្អប្រសើរគឺសូត្រតែតឹកពៀរប៉ុណ្ណោះ។
ការគប់គ្រាប់ក្រួសទាំង៧ក្នុងពេលតែមួយ។
ក្នុងករណីនេះគេចាត់ទុកថាបានតែគ្រាប់ក្រួសមួយប៉ុណ្ណោះ
ដូច្នេះវាជិប(ចាំបាច់)គឺត្រូវគប់គ្រាប់ក្រួសម្តងមួយៗ។
ការដាក់គ្រាប់ក្រួសចូលក្នុងប្រឡោះដុំវិញគោលដោយមិនគប់វា។
នេះមិនត្រឹមត្រូវទេ ច្បាប់តម្រូវឱ្យគប់វាទៅមុខ។
ការផ្តោតលើជញ្ជាំងសំណង់ពេលគប់
និងការយល់ថាគោលដៅគឺគ្រឹះនៃសំណង់។
ដែលត្រឹមត្រូវតាមច្បាប់គឺត្រូវធ្វើយ៉ាងណាឱ្យក្រួសធ្លាក់ក្នុងប្រឡោះដុំវិញគោល
ទោះបីវាមិនប៉ះនឹងសំណង់ក៏ដោយ។
ការគប់ពីចម្ងាយឆ្ងាយ
និងមិនប្រាកដថាក្រួសធ្លាក់ក្នុងប្រឡោះដុំវិញគោល។

ការឈរសុំទូអាបន្ទាប់ពីគប់គ្រាប់ក្លួសនៅជំរំតុលអាក៍ហ្គះ។

នេះមិនត្រឹមត្រូវទេ
ព្រោះគ្មានភស្តុតាងបញ្ជាក់លើការអនុវត្តបែបនេះ។

ការសំឡេះសត្វចំពោះអ្នកធ្វើហាជ្ជីតាម៉ាត់ទួក និងគីរ៉ន មុនថ្ងៃណារ៉។

អ្នកណាដែលធ្វើបែបនេះមិនត្រឹមត្រូវទេ
ហើយចាំបាច់ត្រូវធ្វើម្តងទៀតក្នុងពេលវេលាកំណត់ដោយច្បាប់
គឺថ្ងៃបុណ្យរ៉យ៉ាហាជ្ជីរហូតដល់ចុងថ្ងៃតាស្រិក។

ចង់ចោះបង់ការសំឡេះដើម្បីបរិច្ចាគលុយជំនួសវិញ។

អ្នកណាធ្វើបែបនេះមិនត្រឹមត្រូវទេ
ហើយចាំបាច់ត្រូវតែសំឡេះសត្វ។

ការកោរក្បាល ឬកាត់សក់តែផ្នែកខ្លះនៃក្បាល។

តាមសុណ្ណះគឺត្រូវកោរសក់ ឬកាត់សក់ពេញក្បាល។

ការគិតថាតវ៉ាហ្វគូទូម
(ការដើរជុំវិញកាក់ហ្គះក្នុងពេលមកដល់)
អាចជំនួសតាវ៉ាហ្វអីហ្វាហ្គោះ
ឬធ្វើវាមុនពេលស្ថិតនៅអារ៉ាហ្វះនិងមូហ្សាទើលីហ្វះ។

អ្នកណាដែលធ្វើបែបនេះមិនត្រឹមត្រូវទេ
ព្រោះតវ៉ាហ្វអីហ្វាហ្គោះគឺជាសសរស្តម្ភ(គ្រឹះ)មួយនៃហាជ្ជ ហាជ្ជីមិនត្រឹមត្រូវទេបើគ្មានវា
ហើយមិនអាចធ្វើវាមុនពេលស្ថិតនៅអារ៉ាហ្វះ
និងមូហ្សាទើលីហ្វះបានទេ។

***

ទី៤.

ការប្រព្រឹត្តខុសនិងកំហុសរបស់អ្នកធ្វើហាជ្ជីអំឡុងថ្ងៃមីណា(អែយ៉ាមុល តាស្រ្តិក)។

ការធ្វេសប្រហែសក្នុងការផ្តល់ឱ្យអ្នកតំណាង
និងការផ្ទេរសិទ្ធិក្នុងការគប់គោល

ដែលត្រឹមត្រូវអ្នកធ្វើហាជ្ជីគួរតែគប់គោលដោយខ្លួនឯង
លើកលែងតែមានមូលហេតុស្របច្បាប់ដែលអនុញ្ញាតឱ្យគាត់ចាត់តាំងអ្នកតំណាង។

ការចាកចេញរបស់អ្នកដែលបានចាត់តាំងអ្នកដទៃឱ្យគប់ជំនួសខ្លួន មុនពេលបញ្ចប់ការធ្វើហាជ្ជី

នេះមិនត្រឹមត្រូវទេ។ គាត់ត្រូវស្នាក់នៅមីណា
ឬកន្លែងដែលគាត់កំពុងនៅ
រហូតដល់ការធ្វើហាជ្ជីចប់ បន្ទាប់មកគាត់ហ្វ្រីហ្គើក
ទើបអាចចាកចេញបាន។

ការគប់គោលនៅថ្ងៃតាស្រ្តិក
មុនពេលព្រះអាទិត្យជ្រេ

តាមសុណ្ណៈ ត្រូវគប់គោលបន្ទាប់ពីព្រះអាទិត្យជ្រេ។

ការមិនគប់តាមលំដាប់នៃហ្គាម៉ារ៉ត(គោល)ទាំងបី

ការគប៉តាមលំដាប់គឺរ៉ាជិប(ចាំបាច់)
ដោយគប់ហ្គាម៉ារ៉តទីមួយជាមុន
បន្ទាប់មកហ្គាម៉ារ៉តកណ្តាល
ហើយបន្ទាប់មកហ្គាម៉ារ៉តធំ
ដែលជាហ្គាម៉ារ៉តអាល់អាក៍ហ្គ៉ះ។ អ្នកណាដែលធ្វើច្រាស់

ឬខុសពីលំដាប់នេះ
ត្រូវធ្វើម្តងទៀតតាមលំដាប់ដោយចាប់ផ្តើមពីហ្គាម៉ារ៉ែតតូចមុន ហើយបន្ទាប់មកគប់នៅហ្គាម៉ារ៉ែតបន្ទាប់។

ការឈរសុំទូអាបន្ទាប់ពីគប់គោលចុងក្រោយ(ជាហ្គាម៉ារ៉ែតអាល់អាក់ហ្គះ)

តាមសុណ្ឌះ ត្រូវសុំទូអាបន្ទាប់ពីគប់គោលទីមួយនិងគោលកណ្តាលប៉ុណ្ណោះ។

***

ទី៦.

ការប្រព្រឹត្តខុសនិងកំហុសរបស់មនុស្សក្នុងពេលតវ៉ាហ្វវីហ្គើក

ការតវ៉ាហ្វវីហ្គើកមុនការគប់គោលថ្ងៃចុងក្រោយ: នេះជាកំហុស
ដើម្បីចេញដំណើរស្តាមៗបន្ទាប់ពីគប់គោលរួច។

នេះគឺមិនត្រឹមត្រូវទេ។
អ្នកដែលធ្វើដូច្នេះគឺពិតជាបានធ្វើវាខុសពេលកំណត់របស់វា ដូច្នេះវាមិនត្រឹមត្រូវទេ ហើយគាត់ត្រូវតែធ្វើឡើងវិញបន្ទាប់ពីការគប់គោល។

ការចាត់តាំងអ្នកផ្សេងឱ្យគប់គោលជំនួស ហើយតវ៉ាហ្វមុនពេលអ្នកតំណាងគប់គោល។

អ្វីដែលត្រឹមត្រូវគឺរង់ចាំរហូតដល់ការគប់គោលរួចរាល់ រួចចាំតវ៉ាហ្វវីហ្គើក។

ការមិនបែរខ្នងទៅកាន់កាក់ហ្គះ ដោយចាកចេញដោយថយក្រោយដើម្បីបង្ហាញការគោរពចំពោះកាក់ហ្គះ។

គ្មានភស្តុតាងបញ្ជាក់ឱ្យធ្វើបែបនេះទេ ហើយការចង្អុលបង្ហាញដ៏ល្អបំផុតគឺការចង្អុលបង្ហាញរបស់ណាពីមូហាំម៉ាត់ ﷺ

ការឈរសុំទូអានៅពេលចាកចេញពីម៉ាស្ជិតអាល់ហារ៉ម។

គ្មានភស្តុតាងបញ្ជាក់លើការអនុវត្តបែបនេះទេ។

ការស្នាក់នៅយូរបន្ទាប់ពីតវ៉ាហ្វរីហ្គើកនៅក្នុងម៉ាក្កះដោយគ្មានហេតុផលស្របច្បាប់។

វ៉ាជិប(ចាំបាច់)គឺត្រូវចាកចេញពីម៉ាក្កះភ្លាមៗបន្ទាប់ពីតវ៉ាហ្វរីហ្គើក។មិនមានបញ្ហាឡើយក្នុងការរង់ចាំក្រុមដំណើរ ឬទិញសម្ភារៈធ្វើដំណើរ និងសកម្មភាពស្រដៀងគ្នានេះ។

ប្រសិនបើអ្នកស្នាក់នៅយូរដោយគ្មានហេតុផល អ្នកត្រូវតវ៉ាហ្វរីហ្គើកម្តងទៀត។

ការប្រព្រឹត្តខុស និងកំហុសទាក់ទងនឹងការទស្សនកិច្ចម៉ាស្ជិតណាហ្គារី

ការប៉ះជញ្ជាំង និងរបាំងដែកនៅពេលទស្សនកិច្ចផ្នូររបស់ព្យាការី ﷺ និងការចងខ្សែនៅលើបង្អួចជាការគោរពសក្ការៈដើម្បីទទួលព័រដ័យ។

ពរដ័យគឺនៅក្នុងអ្វីដែលអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ ﷺ បានកំណត់ មិនមែននៅក្នុងប្រការបង្កើតថ្មីៗនោះទេ។

ការទៅល្អាងនៅភ្នំអ៊ូហ៊ូត ដូចជាល្អាងហ៊ីរ៉ក់
និងល្អាងសួរនៅម៉ាក្កៈ ការចងក្រណាត់នៅទីនោះ
និងការទូអាដោយពាក្យទូអាដែលអល់ឡោះមិនបាន
អនុញ្ញាត
និងការទទួលយកការលំបាកក្នុងដំណើរការនេះ។

ទាំងអស់នេះគឺជាការបង្កើតថ្មីដែលគ្មានមូលដ្ឋាន
នៅក្នុងច្បាប់ដែលបានបញ្ជាក់ច្បាស់ឡើយ។

ទស្សនកិច្ចកន្លែងមួយចំនួនដែលពួកគេអះអាង
ថាជាស្លាក់ស្នាមរបស់ព្យាការី ﷺ
ដូចជាកន្លែងជង្គង់អូដ្ឋ និងអណ្តូងចិញ្ចៀន
ឬអណ្តូងអ៊ូស្មាន
និងការយកដីពីកន្លែងទាំងនេះសម្រាប់ពរជ័យ។

ការទូអាសុំពីអ្នកស្លាប់នៅពេលទស្សនកិច្ចផ្នូរហ្គា
គៀក និងផ្នូរអ្នកស្លាប់ក្នុងសមរភូមិអ៊ូហ៊ូត
និងការគប់ប្រាក់នៅទីនោះដើម្បីខិតទៅជិតពួកគេ
និងដើម្បីទទួលបានពរជ័យពីពួកគេ។

ហើយនេះគឺជាកំហុសដ៏ធ្ងន់ធ្ងរមួយ
ហើយវាជាទង្វើស៊ីរីកដ៏ធំបំផុត
ដូចដែលត្រូវបានលើកឡើងដោយអ្នកមានចំណេះដឹង
ហើយដូចដែលមានបញ្ជាក់នៅក្នុងគម្ពីរអាល់គួរអាន
និងស៊ុណ្ណះរបស់ព្យាការីរបស់អល់ឡោះជាម្ចាស់ ﷺ
ពីព្រោះការធ្វើអ៊ីហ្គាទាត់គឺសម្រាប់តែអល់ឡោះតែមួយគត់
ហើយមិនអនុញ្ញាតឱ្យបង្ហែរការគោរពសក្ការៈណាមួយ

ទៅកាន់អ្នកដទៃឡើយ ដូចជាការទូអា សំឡេះ សច្ចា និងអ្វីៗផ្សេងទៀតដែលស្រដៀងគ្នានេះ ដោយសារតែអល់ឡោះទ្រង់មានបន្ទូលថា៖

﴿وَمَآ أُمِرُوٓاْ إِلَّا لِيَعۡبُدُواْ ٱللَّهَ مُخۡلِصِينَ لَهُ ٱلدِّينَ...﴾

(وَمَا أُمِرُوا إِلَّا لِيَعْبُدُوا اللَّهَ مُخْلِصِينَ لَهُ الدِّينَ)(ហើយពួកគេមិនត្រូវបានបញ្ជាឱ្យធ្វើអ្វីផ្សេងក្រៅពីការគោរពសក្ការៈចំពោះអល់ឡោះដោយភាពចិត្តស្មោះសក្តិសាសនារបស់ទ្រង់) [អាល់-ពៃយីណះ ៥]

وصلى الله وسلم على نبينا محمد.

Index

ការប្រពឹត្តខុសក្នុងពេលធ្វើហាដ្ឋី អ៊ុំរ៉ោះ និង ការទស្សនកិច្ច.....2
ការប្រព្រឹត្តខុស និងកំហុសទាក់ទងនឹងការធ្វើអ៊ុំរ៉ោះ.....2
ទីមួយ៖ ការប្រពិត្តខុស និងកំហុសរបស់មនុស្សក្នុងពេលអៀហរ៉ម
.....2
ទី២. ការប្រព្រឹត្តខុសនិងកំហុសឆ្គងរបស់មនុស្សក្នុងពេលតវ៉ាហ្វ
(ការដើរជុំវិញកាក់ហ្គោះ):.....7
ទី៣.
ការប្រព្រឹត្តខុសនិងកំហុសឆ្គងរបស់មនុស្សក្នុងការពេលសាអ៊ុ 13
ទី៤៖ ការប្រព្រឹត្តខុសនិងកំហុសរបស់មនុស្សក្នុងការកោរសក់
ឬកាត់សក់.....15
ការប្រព្រឹត្តខុស និងកំហុសទាក់ទងនឹងពេលធ្វើហាដ្ឋី.....16
ទីមួយ៖ ការប្រព្រឹត្តខុសនិងកំហុសរបស់មនុស្សក្នុងថ្ងៃតារ៉ាយ៉ះ 16
ទី២. ការប្រព្រឹត្តខុសនិងកំហុសរបស់មនុស្សក្នុងថ្ងៃអារ៉ាហ្វ៖.....17
ទី៣.
ការប្រព្រឹត្តខុសនិងកំហុសរបស់មនុស្សក្នុងការធ្វើដំណើរទៅកាន់
មូហ្សូទើលីហ្វ៖ និងការស្នាក់នៅទីនោះ:.....20
ទី៤.
ការប្រព្រឹត្តខុសនិងកំហុសរបស់មនុស្សក្នុងការអនុវត្តទង្វើនៅ
ថ្ងៃណរ៍(ថ្ងៃសំឡេះសត្វ).....22
ទី៤.
ការប្រព្រឹត្តខុសនិងកំហុសរបស់អ្នកធ្វើហាដ្ឋីអំឡុងថ្ងៃមីណា(អៃ
យ៉ាមុល តាស្ត្រិក)។.....25
ទី៦. ការប្រព្រឹត្តខុសនិងកំហុសរបស់មនុស្សក្នុងពេលតវ៉ាហ្វរីហ្គឺក
.....26
ការប្រព្រឹត្តខុស
និងកំហុសទាក់ទងនឹងការទស្សនកិច្ចម៉ាស្ជិតណាហ្គារី.....27